ប្រទេសចិន-ខេត្តយូណាន

云南日报报业集团
YUNNAN DAILY PRESS GROUP

១២

កោះសន្តិភាព | លេខ ៤០ ថ្ងៃ ព្រហស្បតិ៍ ទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០២៤

澜湄传媒 Mekong News Network
云南省南亚东南亚区域国际传播中心
Yunnan Intl Communication Center for South and Southeast Asia

ប្រទេសចិនសព្វថ្ងៃនេះ

ដោយ ÷ គេហទំព័រយូណាន ការសែតយូណានដេលី

កម្លាំងស្ត្រីដែលមានភាពក្រចះក្រចង់ ក្នុងកិច្ចប្រជុំ "សភាទាំងពីរ"

ថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែមករា គឺជាពេលវេលានៃកិច្ចប្រជុំ "សភាទាំងពីរ" របស់ខេត្តយូណាន។ កិច្ចប្រជុំ "សភាទាំងពីរ" ជាការហៅកាត់របស់កិច្ចប្រជុំនៃសភាតំណាងប្រជាជនទូទាំងប្រទេសចិន និងសភាប្រឹក្សានយោបាយប្រជាជនទូទាំងប្រទេសចិន។ កិច្ចប្រជុំ "សភាទាំងពីរ" នៃខេត្តយូណាននៅឆ្នាំនេះ គឺជាកិច្ចប្រជុំលើកទី ២ នៃសភាតំណាងប្រជាជនខេត្តយូណាន នីតិកាលទី ២៤ និងកិច្ចប្រជុំលើកទី ២ នៃសភាប្រឹក្សានយោបាយប្រជាជនខេត្តយូណាន នីតិកាលទី ១៣។ កិច្ចប្រជុំ "សភាទាំងពីរ" គឺជាព្រឹត្តិការណ៍សំខាន់មួយនៅក្នុងជីវិតនយោបាយរបស់ប្រជាជនគ្រប់ជនជាតិក្នុងខេត្តយូណាន។ នៅក្នុងកិច្ចប្រជុំ "សភាទាំងពីរ" នៃខេត្តយូណានឆ្នាំនេះ តំណាងស្ត្រី និងសមាជិកគណៈកម្មាធិការនៃសភាប្រឹក្សានយោបាយប្រជាជន គឺជាទិដ្ឋភាពដ៏ស្រស់ស្អាត ពួកគេបានចែករំលែកកម្លាំងដ៏ខ្លាំងក្លាដែលអាចទ្រ "ផ្ទៃមេឃពាក់កណ្តាល" តាមរយៈការខិតខំប្រឹងប្រែងធ្វើការ។

លោកស្រី ម៉ា គួនយ៉ាន តំណាងនៃសភាតំណាងប្រជាជនខេត្តយូណាន
អ្នកការពារសុវត្ថិភាពផលិតកម្ម

"តើត្រូវការជំហានអ្វីខ្លះដើម្បីប្រែក្លាយរ៉ែឆៅទៅជាលោហៈធាតុ?" ក្រោយឮសំណួរនេះ ម៉ា គួនយ៉ាន តំណាងនៃសភាតំណាងប្រជាជនខេត្តយូណានស្ទាត់នឹងសំណួរនេះណាស់ ដោយសារលោកស្រីបានចូលរួមការងារសំខាន់ៗសម្រាប់ការប្រែក្លាយរ៉ែឆៅទៅជាលោហៈធាតុ។

លោកស្រី ម៉ា គួនយ៉ាន គឺជាបុគ្គលិកជួរមុខនៅរោងចក្រចម្រាញ់នៃក្រុមហ៊ុនរួមប្រើប្រាស់ធនធានឆឹហុង យូណាន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រុមហ៊ុនបានធ្វើការយ៉ាងសកម្មលើជំនាញ ឧបករណ៍ បច្ចេកវិទ្យា និងការគ្រប់គ្រង ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពល និងបង្កើតរូបមន្តផលិតកម្ម បែតងដែលសន្សំសំចៃថាមពល និងកាត់បន្ថយការប្រើប្រាស់។

ប៉ុន្មានឆ្នាំមកនេះ ម៉ា គួនយ៉ាន បានធ្វើការនៅជួរមុខលើការត្រួតពិនិត្យ និងជួសជុល ហើយការពារប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃខ្សែសង្វាក់ផលិតកម្ម។ ទន្ទឹមនឹងនេះដែរ លោកស្រីរៀបចំ និងដឹកនាំសមាជិកក្រុមការិយាល័យ ដើម្បីស្វែងយល់ពីបញ្ហារាំងស្ទះដែលជួបប្រទះក្នុងផលិតកម្ម ដោះស្រាយបញ្ហាលំបាក និងបន្តបង្កើនប្រសិទ្ធភាពបច្ចេកវិទ្យាផលិតកម្ម និងឧបករណ៍ផលិតកម្មនៃផ្នែកចម្រាញ់។

នៅពេលមួយ នៅពេលកែលម្អឧបករណ៍ម៉ាស៊ីនសម្រាប់ទប់កាកសំណល់ ម៉ា គួនយ៉ាន បានដឹកនាំសមាជិកក្រុមឱ្យផ្លាស់ប្តូរប្រតិបត្តិការដោយដៃទៅជាប្រតិបត្តិការអគ្គិសនី ដែលធ្វើឱ្យប្រសើរឡើងយ៉ាងខ្លាំងនូវប្រសិទ្ធភាពប្រតិបត្តិការ និងសុវត្ថិភាពនៃខ្សែផលិតកម្មទាំងមូល។ នៅឆ្នាំ២០១៩ លោកស្រីបានប្តូរការងារពីការត្រួតពិនិត្យ និងជួសជុល ទៅជាអ្នកបញ្ជាសំខាន់សម្រាប់ឡចំហាយកំដៅចម្រាញ់ ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃឡចំហាយ។

ក្នុងនាមជាកម្មករឧស្សាហ៍កម្ម ម៉ា គួនយ៉ាន ប្រៀបធៀបខ្លួនទៅនឹងគ្រាប់វីស។ លោកស្រីនិយាយថា នឹងបន្តពឹងផ្អែកលើឧត្តមានុភាពជំនាញផ្ទាល់ខ្លួន ដើម្បីជួយដោះស្រាយបញ្ហាបច្ចេកទេស និងផលិតកម្មសំខាន់ៗ ធ្វើការងារបានល្អក្នុងការបង្ក្រើន ព្រមទាំងណែនាំ និងបណ្តុះបណ្តាលជំនាញឱ្យកាន់តែមានជំនាញខ្ពស់។

លោកស្រី ណា ពូឡា តំណាងនៃសភាតំណាងប្រជាជនខេត្តយូណាន
"កសិករថ្មី" ដែលស្គាជនបទឡើងវិញ

លោកស្រី ណា ពូឡា ជាលេខាធិការរងនៃសាខាបក្សកុម្មុនិយ្ម៉ូចិននៃភូមិម៉ូអូ ឃុំមីងខា ស្រុកស្វយ័តជនជាតិវ៉ា ស៊ីម៉ឹន ក្រុងភូអឺ និយាយថា "ខ្ញុំសង្ឃឹមថានឹងក្លាយជាស្ពានដែលតភ្ជាប់ស្រុកកំណើតក្នុងក្តីស្រមៃរបស់ខ្ញុំទៅកាន់ពិភពខាងក្រៅ"។

បន្ទាប់ពីបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យក្នុងឆ្នាំ២០១៤ លោកស្រី ណា ពូឡា បានត្រឡប់ទៅស្រុកកំណើតវិញ ហើយបានក្លាយជា "កសិករថ្មី" ដោយចាប់ផ្តើមបង្កើតអាជីវកម្ម។ ក្រោមការដឹកនាំរបស់អ្នកស្រី អ្នកភូមិបានលក់កសិផលតាមរយៈ "ការលក់តាមការបញ្ជាទិញ" និង "ការលក់តាមការផ្សាយផ្ទាល់លើអ៊ីនធើណែត"។ បន្ទាប់ពីការខិតខំប្រឹងប្រែងអស់រយៈពេល ៩ ឆ្នាំ លោកស្រី ណា ពូឡា បានបង្កើតក្រុមហ៊ុនមួយ ហើយបានបង្កើតម៉ាកយីហោពីរ គឺពាក់ព័ន្ធនឹងអនុផលកសិកម្ម និងសិប្បកម្ម ការលក់ប្រចាំឆ្នាំរបស់ក្រុមហ៊ុនបានកើនឡើងពី ៣ ម៉ឺនយ៉ាន់កាលពីដើមដំបូងដល់ជាង ៣ សែនយ៉ាន់នាពេលបច្ចុប្បន្ន ហើយប្រាក់ចំណូលរបស់អ្នកភូមិត្រូវបានកើនឡើង។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវល្បឿនលឿនត្រូវបានកែលម្អ មានភ្ញៀវទេសចរជាច្រើនបានមកឃុំមីងខា។ លោកស្រី ណា ពូឡា បានណែនាំថា "អ្នកភូមិបានបើកភោជនីយដ្ឋាន និងបង្កើតក្រុមសិល្ប:ផ្ទាល់ខ្លួនរបស់ពួកគេ ហើយប្រាក់ចំណូលសេដ្ឋកិច្ចរបស់ពួកគេបានកើនឡើងយ៉ាងខ្លាំង។ សិប្បកម្មតម្បាញជនជាតិវ៉ា ដែលជាបេតិកភណ្ឌវប្បធម៌អរូបីថ្នាក់ជាតិក្នុងស្រុកបានបង្កើតម៉ាកយីហោថ្មីតាមរយៈការរួមផ្សំបែបប្រពៃណី និងសម័យទំនើប។

ប្រជាជនមានការចូលរួមអាហារដ៏ល្អយ៉ាងណា។ រូបថតដោយ លី ផានជូន ឬស្សី ជានីស្យ

ព័ត៌មានសំខាន់ទាំងដប់នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ២០២៣ ត្រូវបានប្រកាសជាផ្លូវការ

ព័ត៌មាន

ដោយ ÷ ការសែតយូណានដេលី

នៅថ្ងៃទី៣១ ខែមករា ពិធីប្រកាសព័ត៌មានសំខាន់ទាំងដប់នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ២០២៣ និងកម្មវិធីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីចិននៅក្រុងប៉េកាំងក្រោមប្រធានបទ "មានការរស់នៅមួយប្រភេទហៅថាយូណាន" បានប្រារព្ធដោយជោគជ័យ។

ព័ត៌មានសំខាន់ទាំងដប់នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ២០២៣ ត្រូវបានជ្រើសរើសក្នុងកម្មវិធីលើកនេះគឺ ៖ ប្រមុខការទូតរដ្ឋដឹកនាំផ្លូវ ការកសាងសហគមន៍ជោគវាសនារួមសម្រាប់ប្រទេសមេគង្គ-ឡានឆាងកាន់តែស៊ីជម្រៅ និងរឹងមាំ។ អ្នកដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងប្រាំមួយមានការផ្លាស់ប្តូរយ៉ាងជិតស្និទ្ធ ហើយការផ្លាស់ប្តូរ និងការជឿទុកចិត្តគ្នាទៅវិញទៅមក ដឹកនាំវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការលើពហុវិស័យ។ និន្នាការនៃការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចដ៏ប្រសើរ ឯការសាងសង់ខ្សែក្រវ៉ាត់អភិវឌ្ឍន៍សេដ្ឋកិច្ចមេគង្គ-ឡានឆាងទទួលបានលទ្ធផលជាផ្លែផ្កា។ ការបង្កើតបរិយាកាសអភិវឌ្ឍន៍ប្រកបដោយសុវត្ថិភាព និងបង្កើតតំបន់ពិសោធន៍ផ្តួចផ្តើមសន្តិសុខជាសកល។ កិច្ចសហប្រតិបត្តិការក្នុងវិស័យឌីជីថលបានរីកដុះដាលក្នុងវិស័យជាច្រើន បញ្ចូលកម្លាំងចលករថ្មីសម្រាប់ "ផ្លូវសូត្រឌីជីថល"។ ការផ្លាស់ប្តូរប្រជាជននិងប្រជាជនមានភាពសម្បូរបែប និងចម្រុះពណ៌ និងរីតបន្តឹងទំនាក់ទំនងមនោសញ្ចេតនារវាងប្រទេសទាំងប្រាំមួយ។ ការកសាងរួមគ្នានូវមាតុភូមិបៃតងនិងស្រស់ស្អាតលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់។ កិច្ចសហប្រតិបត្តិការលើជីវភាពរស់នៅរបស់ប្រជាជនបង្កើនសុភមង្គល និងត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍនិងវិបុលភាពរួម។ កិច្ចសហប្រតិបត្តិការកសិកម្មកំពុងរីកចម្រើន ហើយសមិទ្ធិផលដ៏ផ្អែមល្ហែម ត្រូវបានដាក់នៅលើតុបាយរបស់បណ្តាប្រទេសនានា។ ការប្រមូលផ្តុំប្រាជ្ញានិងកម្លាំងរបស់យុវជន ដើម្បីទទួលអនាគតថ្មីនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

ក្នុងកម្មវិធីនេះ ខេត្តយូណានបានធ្វើការណែនាំ និងការផ្សព្វផ្សាយសំខាន់ក្រោមប្រធានបទ "មានការរស់នៅមួយប្រភេទហៅថាយូណាន" និងរៀបចំតំបន់តាំងពិព័រណ៍ចំនួន ២៣ ដើម្បីបង្ហាញម្ហូបពិសេស ផលិតផលសិប្បកម្ម និងផលិតផលច្នៃប្រឌិតវប្បធម៌មានលក្ខណៈពិសេសជាដើម ដែលនាំមកពីគ្រប់មណ្ឌល(ក្រុង)របស់ខេត្តយូណាន។នៅក្នុងតំបន់ទាញយកបទពិសោធន៍នៃបុណ្យចូលឆ្នាំថ្មីប្រពៃណីចិនដែលមានលក្ខណៈពិសេសខេត្តយូណាន ភ្ញៀវមកពីប្រទេសចិន កម្ពុជា មីយ៉ាន់ម៉ា ឡាវ ថៃ និងវៀតណាម ព្រមទាំងតំណាងមកពីគ្រប់មជ្ឈដ្ឋាន បានចែករំលែក "មានការរស់នៅមួយប្រភេទហៅថាយូណាន" ក្នុងការផ្លាស់ប្តូរ និងទំនាក់ទំនងគ្នាទៅវិញទៅមក។

សហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ត្រូវបានបង្កើតឡើងនៅទីក្រុងប៉េកាំង

នៅថ្ងៃទី៣១ ខែមករា កម្មវិធីបង្កើតសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ បានប្រារព្ធនៅរដ្ឋធានីប៉េកាំងនៃប្រទេសចិន។

សហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ត្រូវបានផ្តួចផ្តើម និងបង្កើតឡើងដោយមជ្ឈមណ្ឌលផ្សព្វផ្សាយអន្តរជាតិចំពោះតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ខេត្តយូណាន និងសាខាអាស៊ីប៉ាស៊ីফিកនៃទីភ្នាក់ងារសារព័ត៌មានកាសែតចិនដេលី ហើយអញ្ជើញប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗ សមាគមអ្នកសារព័ត៌មាន និងស្ថាប័នព័ត៌មានមកពីអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ និងប្រទេសពាក់ព័ន្ធឱ្យចូលរួម។

គម្រោងចំនួន ២១ លើកដំបូងនៃសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ត្រូវបានបើកនៅក្នុងកម្មវិធីនេះ ហើយផែនការសកម្មភាពសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ឆ្នាំ២០២៤ ត្រូវបានចេញផ្សាយជាផ្លូវការ។ ក្នុងឆ្នាំ២០២៤ មជ្ឈមណ្ឌលផ្សព្វផ្សាយអន្តរជាតិចំពោះតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ខេត្តយូណាន នឹងអនុវត្តការផ្សព្វផ្សាយព័ត៌មានទៅវិញទៅមក ការថតវីដេអូ សកម្មភាពផ្ទាស់ប្តូរប្រជាជននិងប្រជាជន ការអភិវឌ្ឍផលិតផលច្នៃប្រឌិតវប្បធម៌ ការផ្សព្វផ្សាយទេសចរណ៍វប្បធម៌ និងគម្រោងផ្សេងៗជាមួយនឹងទីភ្នាក់ងារសារព័ត៌មានកាសែតចិនដេលី អាជ្ញាធរភាសាបរទេសចិន មជ្ឈមណ្ឌលផ្សព្វផ្សាយអន្តរជាតិនៃខេត្តមួយចំនួនក្នុងប្រទេសចិន ក្រុមហ៊ុនពាកព័ន្ធ និងប្រព័ន្ធផ្សព្វផ្សាយសំខាន់ៗក្នុងប្រទេសកម្ពុជា ថៃ ឡាវ នេប៉ាល់ និងប្រទេសផ្សេងៗទៀត។

នៅក្នុងកម្មវិធីថ្ងៃនោះ ផ្ទះអ្នកសារព័ត៌មានអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ត្រូវបានបង្កើតឡើងជាផ្លូវការ។ ទន្ទឹមនឹងនេះដែរ សាខាគុនមីង សាខាឈូស្យូង សាខាវិនសាន និងសាខាលីជាំង នៃមជ្ឈមណ្ឌលផ្សព្វផ្សាយអន្តរជាតិចំពោះតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ខេត្តយូណាន បានប្រគល់ជូនស្ពាកឈ្មោះ និងបង្កើតឡើងជាផ្លូវការផងដែរ។

លោកស្រី ឆេង សួយយួន សមាជិកានៃសភាប្រឹក្សានយោបាយខេត្តយូណាន
អ្នកការពារសុខភាពដី

ក្នុងកិច្ចប្រជុំ "សភាទាំងពីរ" នៅឆ្នាំនេះ លោកស្រី ឆេង សួយយួន សមាជិកគណៈកម្មាធិការនៃសភាប្រឹក្សានយោបាយខេត្តយូណាន បានផ្តោតសំខាន់លើសុខភាពនៃប្រព័ន្ធមីក្រូអេកូឡូស៊ីនៃដី ដើម្បីធ្វើឱ្យសាធារណជនយល់ដឹងអំពីសារៈសំខាន់នៃសុខភាពដី ហើយផ្តួចផ្តើមនូវការការពារ និងការប្រើប្រាស់ធនធានដីប្រកបដោយនិរន្តរភាព។

"សុខភាពរបស់ដីគឺជាអាទិភាពកំពូលនៃប្រព័ន្ធអេកូកសិកម្ម"។ លោកស្រី ឆេង សួយយួន និយាយបែបនេះ។ ក្នុងនាមជាសាស្ត្រាចារ្យ និងជាអនុប្រធាននៃមហាវិទ្យាល័យអេកូ-បរិស្ថាននៃសាកលវិទ្យាល័យយូណាន លោកស្រី ឆេង សួយយួន ជឿជាក់ថា សមត្ថភាពរបស់ខេត្តយូណានក្នុងការពង្រឹងនិងកែលម្អកសិកម្មលក្ខណៈខ្ពង់រាប មិនអាចបំបែកចេញពីអេកូ-បរិស្ថានប្រកបដោយនិរន្តរភាព និងភាពបៃតង ហើយត្រូវរក្សាសុវត្ថិភាពនៃប្រព័ន្ធអេកូឡូស៊ីកសិកម្ម ជាពិសេសសុខភាពនៃប្រព័ន្ធមីក្រូអេកូឡូស៊ីដី។

លោកស្រី ឆេង សួយយួន បានផ្តល់យោបល់ថា ក្រោយពីការណែនាំអំពីការប្រើប្រាស់ជីដោយសមហេតុផល ហិរញ្ញវត្ថុសាធារណៈគួរតែគាំទ្រដល់ដំណាំសំខាន់ៗដូចជាស្បៀងអាហារ ត្រូវការអនុវត្តការការពាររុក្ខជាតិសាធារណៈ ហើយដើរតួនាទីណែនាំរបស់រដ្ឋាភិបាលយ៉ាងពេញលេញ និងបង្កើតផ្លូវសម្រាប់ការការពារប្រព័ន្ធអេកូឡូស៊ីដី ដែលចូលរួមដោយការធានាផ្នែកហិរញ្ញវត្ថុ ការគាំទ្រផ្នែកវិជ្ជាជីវៈនិងបច្ចេកទេស និងការចូលរួមយ៉ាងសកម្មរបស់កសិករ៖

(រូបថតដោយការសែតយូណានដេលី និងផ្តល់ដោយអ្នកទទួលបទសម្ភាសន៍)

អ្នកនិពន្ធភាសាចិន ៖ RAN XIULAN អ្នកនិពន្ធភាសាខ្មែរ ៖ LI ZHA SHEN YAN រចនារូបភាព ៖ SUN YONGGANG